D99/3/12

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នុ័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ២៣ កញ្ញា ២០០៨

---

**សាធារណៈ:**

**សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

| ឯកសារដើម |
|---|
| ORIGINAL DOCUMENT/DOCUMENT ORIGINAL |
| ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 09 / 2008 |
| ម៉ោង (Time/Heure): 14:00 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN |

**ជនត្រូវចោទ**

កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គីមសួន
យុង ផានិត
Silke STUDZINSKY
គីម ម៉េងឃី
Martine JACQUIN
ម៉ុច សុវណ្ណារី

**សហមេធាវីការពារក្តី**

ការ សាវុត្ថ
François ROUX

| ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម |
|---|
| CERTIFIED COPY/COPIE CERTIFIÉE CONFORME |
| ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 09 / 2008 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN |

PRE-TRIAL CHAMBER · CHAMBRE PRELIMINAIRE · E.C.C.C.

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" កត់សម្គាល់ឃើញថា នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ចំពោះដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស (បណ្តឹងឧទ្ធរណ៍) ។

២. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដែលបានដាក់នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ហើយបន្ទាប់មកបានបោះពុម្ពផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គបុរេ-ជំនុំជម្រះកែប្រែដីកាដំណោះស្រាយ ហើយចោទប្រកាន់ជនត្រូវចោទចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

៣. វិធាន ៣៣ នៃវិធានផ្ទៃក្នុងចែងថា:

១. នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចអញ្ជើញ ឬ ផ្តល់ឱកាសឲ្យអង្គការ ឬ បុគ្គលណាមួយប្រគល់ជូននូវសារណាជាលាយល័ក្ខអក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បានក្នុងនាមជាអ្នកឯកទេសអមតុលាការ។ សហចៅ-ក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ដែលពាក់ព័ន្ធត្រូវកំណត់ពេលវេលាឲ្យដាក់សារណានេះ ប្រសិនបើត្រូវធ្វើ។

២. សារណាដែលធ្វើឡើងក្រោមវិធាននេះ ត្រូវប្រគល់ទៅឲ្យក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលពាក់ព័ន្ធ។ ក្រឡាបញ្ជីត្រូវប្រគល់ឯកសារថតចម្លងមួយច្បាប់ទៅឲ្យសហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីដទៃទៀត ដើម្បីមានឱកាសធ្វើការឆ្លើយតប។

៤. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ដើម្បីធ្វើការវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍នេះឱ្យបានត្រឹមត្រូវ វាជាការសមស្របក្នុងការអញ្ជើញសាស្ត្រាចារ្យ Antonio Cassese ដែលជានិពន្ធនាយកសម្រាប់ *ទនានុប្បវត្តិនៃតុលាការយុត្តិធម៌អន្តរជាតិ* សមាជិកនៃក្រុមប្រឹក្សានិពន្ធផ្សេងទៀត ព្រមទាំងគណៈកម្មាធិការនិពន្ធនៃ *ទនានុប្បវត្តិ* ឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរ ចំពោះបញ្ហាដូចខាងក្រោម:

(១) ការវិវត្តន៍នៃទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម និងការវិវត្តន៍និយមន័យនៃទម្រង់នៃការទទួលខុសត្រូវនៃទ្រឹស្តីមួយនេះ ដោយចង្អុលយោងជាក់លាក់លើអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩។

(២) តើសហកម្មឧក្រិដ្ឋកម្មរួម ជាទម្រង់នៃការទទួលខុសត្រូវមួយបែប ដែលអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដែរឬទេ បើសិនធ្វើការពិចារណាលើករណីដែលថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងឆ្នាំ ១៩៧៥ និង ឆ្នាំ១៩៧៩។

៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីណែនាំលើទម្រង់នៃសារណាជាលាយលក្ខណ៍អក្សរ អាចពិនិត្យមើលនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក *សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/ ០១/២០០៧/វ០២* ដែលមាននៅលើគេហទំព័រនៃ អ.វ.ត.ក។

**ដូច្នេះ អង្គបុរេជំនុំជម្រះ÷**

អញ្ជើញសាស្ត្រាចារ្យ **Antonio Cassese** ដែលជានិពន្ធនាយកសម្រាប់ *ទនានុប្បវត្តិនៃតុលាការយុត្តិធម៌អន្តរជាតិ* សមាជិកនៃក្រុមប្រឹក្សានិពន្ធផ្សេងទៀត ព្រមទាំងគណៈកម្មាធិការនិពន្ធនៃ *ទនានុប្បវត្តិ* ឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរ មិនលើសចំនួនសាមសិប(៣០)ទំព័រ ជាភាសាអង់គ្លេស និង/ឬក៏ជាភាសាបារាំង ចំពោះបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីអញ្ជើញនេះ ឱ្យបានត្រឹមថ្ងៃទី **២៧ ខែតុលា ឆ្នាំ២០០៨** ។

ភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ប្រាក់ គឹមសាន